# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌
លេខ ១៤៩៣ អក/៩៩

# រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបមក**

**លោក ព្រះរាជអជ្ញាអមតុលាការក្រុងព្រះសីហនុ**

**សូមជ្រាប។**

**កម្មវត្ថុ:** អំពីការចោទប្រកាន់លើទណ្ឌិត ឬ ពិរុទ្ធជនដែលប្រព្រឹត្តបទល្មើសថ្មី ។

**យោង:** របាយការណ៍លេខ៨៥ រប-៩៩ចុះថ្ងៃទី២៥-០៦-៩៩របស់លោកព្រះរាជអាជ្ញាអមតុលាការក្រុងព្រះសីហនុ។

ខ្ញុំសូមជម្រាបលោកថា ករណីទណ្ឌិតនិងពិរុទ្ធជនចំនួន៣៥នាក់ ដែលប្រើអំពើហឹង្សារត់ចេញពីពន្ធនាគារក្រុងព្រះសីហនុកាលពីថ្ងៃទី១៧-០៦-៩៩ ចាត់ទុកថា ជាបទល្មើសព្រហ្មទណ្ឌថ្មីមួយទៀត ទណ្ឌិតឬពិរុទ្ធជនទាំងអស់នេះទោះបីចាប់បានមកវិញ ឬមិនទាន់ចាប់បានក៏ដោយ ក៏ត្រូវលោកព្រះរាជអាជ្ញាចាត់ការតាមនីតិវិធីច្បាប់ជាធរមានដូចជាបទល្មើសបំផ្លិចបំផ្លាញទ្រព្យសម្បត្តិសាធារណៈ ឬទ្រព្យសម្បត្តិរដ្ឋឬបង្ករបួសស្នាមដោយចេតនាបទល្មើសផ្សេងៗទៀតដែលជនទាំងនោះបានប្រព្រឹត្តលើ មន្ត្រីពន្ធនាគារជាដើម ។

ឆ្លើយតបនឹងរបាយការណ៍ដូចបានយោងខាងលើ ក្រសួងយុត្តិធម៌សូមឱ្យលោកព្រះរាជអាជ្ញាត្រូវតែបន្តចាត់វិធានការតាមច្បាប់ តាមរកចាប់ទណ្ឌិត ឬពិរុទ្ធជនដែលរត់គេចខ្លួនចេញពីមន្ទីរឃុំឃាំង នឹងពន្ធនាគារក្រុងព្រះសីហនុ ហើយដែលពុំទាន់ចាប់បានមកវិញនៅឡើយនោះឱ្យបានទាំងអស់យកមកឃុំខ្លួន ហើយផ្តន្ទាទោសពីបទល្មើសផ្សេងៗដែលបានប្រព្រឹត្តសមស្របតាមច្បាប់និងនីតិវិធីជាធរមាន ។

អាស្រ័យហេតុនេះសូមលោកចាត់ការតាមការណែនាំខាងលើ ឱ្យមានប្រសិទ្ធិភាពខ្ពស់ដើម្បីការពារផលប្រយោជន៍ច្បាប់តទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩៩

**រដ្ឋមន្ត្រី**

**អ៊ុក វិធុន**

ចម្លងជូន
-លោកព្រះរាជអាជ្ញាអមតុលាការខេត្ត.ក្រុង
-លោកប្រធានតុលាការខេត្តក្រុង
-ដើម្បីជ្រាបនឹងអនុវត្ត